# មេរៀនសង្ខេប

- រុក្ខជាតិអង់ស្យូស្ពែមមាននៅគ្រប់ទីកន្លែងលើផែនដីទោះជានៅតំបន់ត្រជាក់តំបន់ព្រៃត្រូពិចនៅវាលខ្សាច់ដែលគ្មានជីជាតិ ឬនៅតំបន់មាត់សមុទ្រ ។ រុក្ខជាតិអង់ស្យូស្ពែមមានលក្ខណៈពិសេសពីរយ៉ាងគឺមានផ្កាដែលជាសរីរាង្គភេទនិងគ្រាប់ដែលការពារដោយសំបក ។
- សរីរាង្គភេទរបស់រុក្ខជាតិអង់ស្យូស្ពែម គឺផ្កា ។ ផ្កាផ្គុំឡើងដោយត្របក ស្រទាប់ កញ្ចុំកេសរឈ្មោលនិងកញ្ចុំកេសរញី។ កញ្ចុំកេសរឈ្មោលរួមមាន ប្លោកលំអងនិងទងកេសរឈ្មោល ។ កញ្ចុំកេសរញីមានស្ទិចម៉ាត កកេសរញី និងអូវែមាន អូវុលនៅខាងក្នុង ។
- ដំណើរលំអងមានពីរយ៉ាងគឺ ស្វ័យដំណើរលំអងនិងដំណើរលំអងកាត់ ។ ដំណើរលំអងកាត់ ប្រព្រឹត្តឡើងដោយសារទឹក ខ្យល់ និងសត្វ ។ គ្រាប់លំអងធ្លាក់លើស្ទិចម៉ាតចូលតាមកកេសរ ញី រួចទៅដល់អូវែ ។ នៅទីនោះ វាភ្ជាប់ជាមួយអូវុល បង្កើតបានជាស៊ីកូត ។ ស៊ីកូតលូតលាស់ ជាអំប្រ៊ីយ៉ុងដែលជាផ្នែកមួយនៃគ្រាប់ ។
- រុក្ខជាតិអង់ស្យូស្ពែមមានពីរក្រុមធំៗ : រុក្ខជាតិម៉ូណូកូទីលេដូននិងឌីកូទីលេដូន ។
- រុក្ខជាតិនេះសារៈប្រយោជន៍ ចំពោះជីវភាពរស់នៅរបស់មនុស្សយើង។ ស្រល់អាចយកទៅធ្វើជាក្រដាស គ្រឿងសង្ហារឹម និងចំហុយធ្វើជាប្រេងសម្រាប់លាបឈើនិងផ្ទះ។គេក៏អាចយកប្រេងដែលបានមកពីរុក្ខជាតិផ្សេងទៀតមកព្យាបាលជំងឺ ផងដែរ។ ឯរុក្ខជាតិអង់ស្យូស្ពែមជាប្រភពអាហារដ៏សំខាន់។ គេយកវាទៅផលិតជាសំពត់ ក្រដាស  និងឱសថសម្រាប់ ព្យាបាលជំងឺ ។ មិនតែប៉ុណ្ណោះ៖ គេអាចយកវាទៅធ្វើជាគ្រឿងប្រើប្រាស់ សង់ផ្ទះ៖ ធ្វើគ្រឿងសង្ហារឹមដ៏ប្រណិត ទៀតផង ។ ជាពិសេស រុក្ខជាតិផ្តល់អុកស៊ីសែន ដែលជាផលិតផលនៃដំណើររស្មីសំយោគ ដល់ជីវិតមនុស្សនិងសត្វ។
- ស៊ីឡែម៖ ដឹកនាំទឹក និងអំបិលខនិជពីឫសទៅដើម និងស្លឹក។
- ផ្លូអែម៖ ដឹកនាំអាហារទៅគ្រប់កោសិកាទាំងអស់របស់រុក្ខជាតិដែលមិនអាចធ្វើរស្មីសំយោគបាន។